**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩

**សណ្ឋាគារសេដ្ឋាមិត្តភាព ខេត្តកែប**
**ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម **អ៊ឹង ឆាយ** អភិបាលរងខេត្តកែប តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា*
- *ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សរីករាយដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩**" ។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនាពេលនេះផងដែរ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងជ្រាលជ្រៅជូន

ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គនាពេលនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីចូលរួមចំណែកដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍នៅគ្រប់លំដាប់ថ្នាក់ រហូតទទួលបានជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៩នេះ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដាក់ចេញនូវវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវការជំរុញលើកទឹកចិត្តកាន់តែខ្លាំងក្លាបន្ថែមទៀត ដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការបំពេញការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ខ្ញុំក៏សូមថ្លែងអំណរគុណនិងកោតសរសើរផងដែរចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨ ដែលបានលើកគំនិតប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងបង្កើតឱ្យមានសេចក្តីសម្រេចចិត្តដ៏ល្អមួយ នាំដល់ការស្នើសុំរាជរដ្ឋាភិបាលសម្រេចចេញនូវវិធានការខាងលើប្រកបដោយមោទនភាព។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

អនុញ្ញាតឱ្យខ្ញុំរំឭកជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងផ្អែកតាមគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវប្រារព្ធឡើងជាទៀងទាត់រៀងរាល់៦ខែម្តង ដូច្នេះកិច្ចប្រជុំនាថ្ងៃនេះគឺជាកិច្ចប្រជុំលើកទី១ ដើមឆ្នាំ២០១៩ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពនៃការឆ្លើយតបជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៩ រួមជាមួយនឹងការប្រើប្រាស់នូវឱកាសដ៏ប្រពៃនេះ សិក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងជាពិសេសពិភាក្សារួមគ្នាទៅលើចំណុចខ្វះខាតមួយចំនួនដែលត្រូវការនូវដំណោះស្រាយតាមរយៈការចូលរួមរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានវត្តមាននៅពេលនេះ។ លើសពីនេះអង្គប្រជុំ នឹងមានដាក់ចេញនូវសេចក្តីសម្រេចជាគោលការណ៍មួយចំនួនសម្រាប់ឱ្យក្រុមការងារបច្ចេកទេសយកទៅប្រើប្រាស់ក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពគន្លឹះរយៈពេល៦ខែចុងឆ្នាំ២០១៩ ជាបន្តទៀត។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

សមិទ្ធផលដែលគួរជាទីមោទនៈ ដែលសមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រេចបាននៅក្នុងឆ្នាំ២០១៨ គឺទទួលបាននូវការគាំទ្រជានយោបាយដ៏មោះមុតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈការដាក់ចេញនូវ "សេចក្តីជូនដំណឹង លេខ២១៣សជណ.សស" ដែលជាមគ្គុទេសក៍ជាតិមួយសម្រាប់យើងទាំងអស់គ្នាប្រើប្រាស់ក្នុងការរៀបចំជាផែនការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍អង្គប្រជុំថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់ជំងឺអេដស៍ តាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលដៅសូន្យបី គឺ "គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ និងគ្មានការស្លាប់ដោយសារជំងឺអេដស៍" និងឆ្ពោះទៅសម្រេចបានគោលដៅយុទ្ធសាស្ត្រ ៩៥ ៩៥ ៩៥ (៩៥% នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេ ៩៥% នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យហើយ បានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩៥% នៃអ្នកទាំងអស់ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន) នៅឆ្នាំ២០២៥។

ជារួមប្រទេសកម្ពុជាយើងកំពុងតែឈរនៅលើផ្លូវត្រូវ យើងកំពុងតែធ្វើត្រូវក្នុងក្តីសង្ឃឹមពិតប្រាកដឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍តាមការកំណត់ ដោយសារតែប្រទេសកម្ពុជាយើងមានកត្តាចាំបាច់ដ៏មានប្រសិទ្ធភាពខ្ពស់រួចទៅហើយ គឺការប្តេជ្ញាចិត្តគាំទ្រជានយោបាយ ប្រកបដោយទស្សនវិស័យវែងឆ្ងាយ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រួមជាមួយនឹងកត្តាគ្រប់គ្រាន់មួយចំនួនគឺ ៖ មានចីរភាពនៃការចូលរួមឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ និងការចូលរួមជាដៃគូនៃប្រទេសជាមិត្ត និងស្ថាប័នអន្តរជាតិ សង្គមស៊ីវិល ឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ល។ មានប្រព័ន្ធតាមដានការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍បានជាប្រចាំ មានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ដូចជាប្រទេសនានាក្នុងសាកលលោក និងក្នុងតំបន់ដែរ បញ្ហាដែលកម្ពុជាកំពុងបន្តប្រឈមមកដល់ពេលនេះ និងទៅខាងមុខគឺជាបញ្ហាធនធានមនុស្សដែលទាមទារនូវការកសាងសមត្ថភាពពេញលេញពីយុទ្ធសាស្ត្រវិទ្យាសាស្ត្រថ្មីៗ ធនធានសម្ភារបរិក្ខារក្នុងការប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាន និង

ធនធានថវិកាដែលជាបញ្ហាប្រឈមខ្ពស់ជាងគេក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍។ ដូច្នេះ ទាមទារនូវការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រើប្រាស់គ្រប់លទ្ធភាពទាំងអស់ ក្នុងការចលនាធនធានពីគ្រប់ប្រភពទាំងអស់ រួមជាមួយនឹងការធានាដល់ការចំណាយធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយចៀសវាងឱ្យបាននូវការចំណាយច្រើន ទទួលបានផលតិច ឬការចំណាយជាន់គ្នា។ល។

នៅចុងបញ្ចប់ ខ្ញុំសូមជូនពរឱ្យកិច្ចប្រជុំនេះ ដំណើរការប្រកបដោយផ្លែផ្កាក្រោមការពិភាក្សាយ៉ាងសកម្មដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតគំនិតគន្លឹះសំខាន់ៗបន្ថែមទៀត សម្រាប់ផ្តល់ជូនអ្នកបច្ចេកទេសអាចយកទៅប្រើប្រាស់ក្នុងការបន្តការរៀបចំ អនុវត្ត និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រីទទួលបាននូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ ២០១៩**” ជាផ្លូវការចាប់ពីពេលនេះតទៅ!

***សូមអរគុណ!***